# តួនាទីរបស់ពួកជំនុំនៅក្នុងសង្គម
# Role of the Church in Society

## សេចក្តីសង្ខេបៈ

របៀបរបរៈធំរបស់ព្រះជាម្ចាស់គឺជាការផ្សះផ្សា និងស្តារឡើងវិញរបស់សព្វសារពើទាំងអស់ដែលបានខូចខាំនៅក្នុងការធ្លាក់ចុះ។ របៀបវារៈនេះនឹងមិនចប់សព្វគ្រប់ឡើយ រហូតដល់ព្រះគ្រីស្ទយាងត្រលប់មកវិញ។ ប៉ុន្តែទម្រាំទៅដល់ពេលនោះ ព្រះជាម្ចាស់បានបង្កើតពួកជំនុំឡើងឱ្យធ្វើជាឧបករណ៍ដ៏ចម្បងដើម្បីសម្រេចរបៀបវារៈនោះនៅលើផែនដី។

## គំនិតចម្បងៈ

១. ព្រះជាម្ចាស់ស្រលាញ់ស្នាព្រះហស្ត**ទាំងអស់**ដែលព្រះអង្គបានបង្កើត ហើយហៅថាល្អ បន្ទាប់មកបានបញ្ជាក់សេចក្តីស្រលាញ់របស់ព្រះអង្គឡើងវិញតាមរយៈសេចក្តីតាំងសញ្ញាជាមួយស្នាព្រះហស្ត**ទាំងអស់** រួមមានទាំងធម្មជាតិ បុគ្គលម្នាក់ៗ និងប្រជាជាតិទាំងឡាយ។

២. ការប្រោសលោះរបស់សព្វសារពើ**ទាំងអស់**ដែលបានបាក់បែកនៅក្នុង**ការធ្លាក់ចុះ** បានចប់សព្វគ្រប់តាមរយៈព្រះលោហិតរបស់ព្រះគ្រីស្ទដែលបានកំចាយមក ប៉ុន្តែការស្តារឡើងវិញគឺជាដំណើរការដែលចេះតែបន្ត ហើយនឹងចប់សព្វគ្រប់ នៅពេលដែលព្រះគ្រីស្ទយាងត្រលប់មកវិញធ្វើជាស្តេច។

៣. ពួកជំនុំគឺជាឧបករណ៍ដ៏ចម្បងដែលព្រះជាម្ចាស់បានជ្រើសរើសយកសម្រាប់សម្រេចកិច្ចការផ្សះផ្សា និងស្តាររបស់សព្វសារពើ**ទាំងអស់**ឡើងវិញ រហូតដល់ព្រះគ្រីស្ទយាងត្រលប់មកវិញ។

៤. ភារកិច្ចចុងក្រោយរបស់អំណោយទានដឹកនាំទាំងអស់នៅក្នុងពួកជំនុំ គឺបណ្តុះបណ្តាលពួកអ្នកជឿសម្រាប់ធ្វើកិច្ចការបម្រើដោយសេចក្តីស្រឡាញ់។

## លទ្ធផលៈ

១. ឥឡូវនេះ:

ក. យល់ និងនិយាយប្រាប់គំនិតចម្បងរបស់មេរៀន ដោយប្រើពាក្យរបស់ខ្លួនគេ។

ខ. រៀបចំផែនការ និងអនុវត្តជំហានថ្មីមួយនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់ពួកគេ ជាការឆ្លើយតបចំពោះមេរៀននេះតាមរយៈសកម្មភាពបម្រើជាក់ស្តែងប្រកបដោយសេចក្តីស្រឡាញ់។

២. ទៅមុខទៀត

ក. ស្គាល់ចំណុចណាមួយនៅក្នុងរបៀបវារៈរបស់ព្រះជាម្ចាស់សម្រាប់ចក្រវាឡ ដែលពួកគេមិនបានធ្វើឱ្យរីកចម្រើនឡើងនៅពេលបច្ចុប្បន្ននេះ ប្រែចិត្ត និងប្តេជ្ញាចិត្តធ្វើឱ្យរបៀបវារៈទាំងមូលរបស់ព្រះជាម្ចាស់រីកចម្រើនឡើងចេញពីអ្វីដែលបានរៀន។

ខ. ធ្វើជាអ្នកដឹកនាំដើម្បីបណ្តុះបណ្តាលអ្នកជឿដទៃទៀតសម្រាប់កិច្ចការបម្រើដោយសេចក្តីស្រលាញ់ ដើម្បីចូលរួមនៅក្នុងរបៀបវារៈរបស់ព្រះជាម្ចាស់ក្នុងការផ្សះផ្សា និងស្តារអ្វីៗ**ទាំងអស់**ឡើងវិញ។

# តួនាទីរបស់ពួកជំនុំនៅក្នុងសង្គម

## គ្រោងមេរៀន

## ១. សេចក្តីផ្តើម

## ២. ការសន្មត់

ក. ពិភពលោកខ្មេចខ្ទាំយ៉ាងអស់សង្ឃឹម ។

ខ. ប្រាជ្ញាវាងវៃបំផុតរបស់យើងនឹងមិនប្រោសឱ្យយើងជាទេ ។

គ. ការប្រោសឱ្យជាមកតាមរយៈជំនឿ និងការស្តាប់បង្គាប់ ។

ឃ. ព្រះគម្ពីរគឺជាការបើកសំដែងរបស់ព្រះជាម្ចាស់សម្រាប់ការប្រោសឱ្យជារបស់យើង ។

ង. យើងនៅលើផែនដីនេះដោយព្រោះមានគោលបំណង ។

## ៣. ព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ចំពោះស្នាព្រះហស្តដែលព្រះអង្គបង្កើត

ក. ព្រះអង្គបានបង្កើត ។

ខ. ព្រះអង្គបានវាយតម្លៃភាពល្អនៃស្នាព្រះហស្តរបស់ព្រះអង្គ ។

គ. ការវាយតម្លៃចុងក្រោយរបស់ព្រះអង្គ។

## ៤. សេចក្តីសញ្ញារបស់ព្រះជាម្ចាស់ជាមួយគ្រប់ទាំងជីវិត

ក. ណូអេ និងគ្រួសាររបស់គាត់។

ខ. គ្រប់ទាំងជីវិត។

## ៥. ព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ចំពោះគ្រប់ទាំងជំនាន់

ក. ណូអេ

ខ. អ័ប្រាហាំ

## ៦. ព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ចំពោះគ្រប់ទាំងសាសន៍

ក. **គ្រប់ទាំងសាសន៍**នៅផែនដីនឹងបានពរ (លោកុប្បត្តិ ២២:៨)។

ខ. អ៊ីស្រាអែលជាសង្ឃដល់**អស់ទាំងសាសន៍** (ចោទិយកថា ៤:៥-៨)។

គ. ព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ថានឹងប្រោស**ស្រុក**ឱ្យបានជា (២ របារក្សត្រ ៧:១៤)។

ឃ. **គ្រប់ទាំងសាសន៍**គេនឹងរត់មកឯឯង ដោយព្រោះ... (ទំនុកដំកើង ២:៨, អេសាយ ៥៥:៣-៥)។

ង. សេចក្តីសប្បុរសរបស់ព្រះជាម្ចាស់សម្រាប់**សាសន៍**ដែលមានបាប (យ៉ូណាស ៣:៨-៤:២)។

ច. កិត្តិយសនៅកណ្តាល**អស់ទាំងសាសន៍** (អេសោគាល ២០ និង ៣៦)។

ឆ. ដំណឹងល្អនឹងត្រូវប្រកាសទុកជាសេចក្តីបន្ទាល់ដល់**អស់ទាំងសាសន៍** ( លូកា ២៤:៤៧) ។

ជ. បញ្ចុះបញ្ចូលឱ្យមានសិស្សនៅ**គ្រប់ទាំងសាសន៍** ( ម៉ាថាយ ២៨:១៩) ។

ឈ. ព្រះជាម្ចាស់ទទួលយកមនុស្សមកពី**គ្រប់ទាំងសាសន៍** ( កិច្ចការ ១០:៣៤-៣៥) ។

ញ. **អស់ទាំងសាសន៍**នឹងដើរក្នុងពន្លឺក្រុងនោះ (វិវរណៈ ២១:១៤) ។

## ៧. គោលបំណងច្រោសលោះរបស់ព្រះជាម្ចាស់

ក. កូល៉ុស ១:១៥-២០

ខ. ហេតុអ្វីបានជាព្រះយេស៊ូវបានកំចាយព្រះលោហិតរបស់ព្រះអង្គ?

## ៨. ពួកជំនុំ និងគោលបំណងច្រោសលោះរបស់ព្រះជាម្ចាស់

ក. អេភេសូរ ១:២២-២៣ ពួកជំនុំ =

ខ. អេភេសូរ ៣:១៧-១៩ សេចក្តីពោរពេញរបស់ព្រះ =

គ. អេភេសូរ ៤:១១-១៣ កិច្ចការបម្រើ ➔ ការរួបរួម + ភាពពេញវ័យ

ភាពពេញវ័យ =

ឃ. អេភេសូរ ៣:២០ ហួសសន្ធឹកលើសជាង: **គ្រប់ទាំងអស់** -សាសន៍ទាំងឡាយរបស់យើង

## ៩.	គោលបំណងប្រោសលោះរបស់ព្រះជាម្ចាស់តាមរយៈពួកជំនុំ

ក.	អេភេសូរ ៣:៩-១០	ប្រាជ្ញាដ៏មានជាច្រើនយ៉ាងរបស់ព្រះជាម្ចាស់

(គោលបំណងប្រោសលោះរបស់ព្រះជាម្ចាស់)




## ១០.	របៀបដែលសាសន៍មួយត្រូវបានបញ្ចុះបញ្ចូលឱ្យទៅជាសិស្ស




## ១១.	ជំនឿសំខាន់ៗរបស់ពួកជំនុំដំបូង

ក.	ព្រះដែលស្រលាញ់អ្នកដែលស្រលាញ់ព្រះអង្គ។

ខ.	ព្រះដ៏មានសេចក្តីមេត្តាករុណាដែលតម្រូវឱ្យមានសេចក្តីមេត្តាករុណា។

គ.	វប្បធម៌ដែលគ្មានជាតិសាសន៍ និងវណ្ណៈ។

ឃ. បុរសត្រូវស្រលាញ់ប្រពន្ធដូចខ្លួនឯង។

ង. ការបដិសេធនៃការរំលូតកូន និងការសំលាប់ទារក។

ច. ស្រលាញ់ដល់អ្នកជឿ និងលើសពីនោះ - មើលថែអ្នកឈឺ។

## ១២. មូលហេតុនៅក្នុងប្រវត្តិសាស្ត្រ — ហេតុអ្វីមិនមាននៅសព្វថ្ងៃនេះ?

ក. ប្រតិកម្មចំពោះដំណឹងល្អសម្រាប់សង្គម / សេរីនិយម

ខ. ព័ន្ធកិច្ចបម្រើសេចក្តីត្រូវការខាងសាច់ឈាម - មធ្យោបាយឆ្ពោះទៅចុងបញ្ចប់

គ. ការសិក្សាដែលមានលក្ខណៈទុទ្ធិដ្ឋិនិយមអំពីគ្រាចុងក្រោយ (ទស្សនៈអំពីអនាគត)

ឃ. ការមិនបានដឹងអំពីនគររបស់ព្រះជាម្ចាស់នៅក្នុងពេលបច្ចុប្បន្ន

ង. បិតុនិយម

១. ទស្សនៈអំពីភាពក្រីក្ររបស់អ្នកដែលកំពុងត្រូវបានផ្សាយដំណឹងល្អឱ្យ និងកំពុងត្រូវបានបង្រៀន

២. ការបង្រៀនអំពីតួនាទីជាអ្នកមើលការខុសត្រូវនៅខ្សោយ

៣. គំរូព័ន្ធកិច្ចជាស្ថាប័នមិនមាននិរន្តរភាព

## ១៣. អំពើបាបដោយអចេតនារបស់ពួកជំនុំ

ក. អេសាយ ៥៨

ខ ៤ "ការដែលឯងតមអត់នោះ គឺមិនមែនមានប្រយោជន៍ឱ្យសំឡេងឯងបានឮទៅដល់ស្ថានលើឡើយ។

ខ ១-៥ ការថ្វាយបង្គំដែលព្រះជាម្ចាស់មិនទទួលយក។

ខ ៦-៧ ការថ្វាយបង្គំដែលព្រះជាម្ចាស់ទទួលយក។

ខ ៨-៩ សេចក្ដីសន្យាអំពីការប្រោសឱ្យជា។

ខ ៩-១០ ការថ្វាយបង្គំដែលព្រះជាម្ចាស់ទទួលយក។

ខ ១០-១២ សេចក្ដីសន្យាអំពីការប្រោសឱ្យជា។

ខ ១៣ ការថ្វាយបង្គំដែលព្រះជាម្ចាស់ទទួលយក។

ខ ១៤ សេចក្ដីសន្យាអំពីការប្រោសឱ្យជា។

ខ. ការថ្វាយបង្គំដែលមិនអាចកែប្រែបាន

១. យេរេមា ២២:១៥-១៦

២. មីកា ៦:៨

គ. លេវីវិន័យ ៤ និង ៥

៤:១៣-២១ អំពើបាបរបស់សហគមន៍

៤:២២-២៦ អំពើបាបរបស់អ្នកដឹកនាំ

៤:២៧:៣១ អំពើបាបរបស់បុគ្គល

ឃ. ការឆ្លើយតបចំពោះអំពើបាបដោយអចេតនា

១. ការបានដឹង

២. ការថ្វាយតង្វាយ / ការប្រែចិត្ត

៣. ការថ្វាយតង្វាយឱ្យធួននឹងបាប / ការអត់ទោស

៤. ការផ្លាស់ប្តូរអាកប្បកិរិយា - អាកប្បកិរិយាដែលឆ្លុះបញ្ចាំងឱ្យឃើញបំណងព្រះហឫទ័យរបស់ព្រះ

ង. រ៉ូម ១២:១-២

១. ដូច្នេះ...ចូរឱ្យបានផ្លាស់ប្រែ...

២. ការផ្លាស់ប្រែ = ការផ្លាស់ប្តូរអាកប្បកិរិយា

៣. អាកប្បកិរិយាដែលឆ្លុះបញ្ចាំងឱ្យឃើញបំណងព្រះហឫទ័យរបស់ព្រះ

## ១៤. ការអនុវត្តន៍ ~ ផ្ទាល់ខ្លួន និងរួមគ្នា

ក. ផ្ទាល់ខ្លួន

១. ការឆ្លុះបញ្ចាំង

២. ផែនការអនុវត្ត

៣. ការប្តេជ្ញាចិត្ត

ខ. រួមគ្នា

១. ការឆ្លុះបញ្ចាំង

២. ផែនការអនុវត្ត

៣. ការប្តេជ្ញាចិត្ត

៤. ចែកចាយ និងអធិដ្ឋាន

# តួនាទីរបស់ពួកជំនុំនៅក្នុងសង្គម
## មេរៀន

តើពួកជំនុំមានតួនាទីអ្វីនៅក្នុងពិភពលោកនេះ? តើព្រះជាម្ចាស់មានរបៀបវារៈយ៉ាងដូចម្ដេចសម្រាប់ពួកជំនុំ? យើងនឹងមើលឃើញរបៀបដែលព្រះជាម្ចាស់ចង់ឱ្យពួកជំនុំបង្ហាញសេចក្ដីស្រលាញ់របស់ទ្រង់នៅក្នុងពិភពលោកនេះ ។

### ការសន្មត់ជាមូលដ្ឋានគ្រឹះ

នៅពេលដែលយើងចាប់ផ្ដើម យើងត្រូវពិនិត្យមើលការសន្មត់ជាច្រើន ។ វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការដែលយល់ថាពាក្យ ទៅវិញទៅមក ចេញមកពីកន្លែងណា នៅពេលដែលយើងរៀនជាមួយគ្នា។ ទីមួយ ដោយយើងជាមនុស្សជាតិ ***យើងខ្ទេចខ្ទាំយ៉ាងអស់សង្ឃឹម ហើយប្រាជ្ញាវាងវៃបំផុតរបស់យើងនឹងមិនប្រោសយើងឱ្យជាឡើយ ។*** ព្រះគម្ពីរប្រាប់យើងយ៉ាងដូច្នេះ ។ ឧទាហរណ៍មួយគឺថា នៅក្នុងរយៈពេលម្ភៃឆ្នាំកន្លងមកនេះ មានទីភ្នាក់ងាររាប់រយដែលផ្ដោតកំឡាំងរបស់ពួកគេទៅលើប្រទេសកោះតូចមួយ គឺប្រទេសហៃទី ដែលមានមនុស្សប្រាំបួនលាននាក់រស់នៅលើកោះតូចនេះ ។ លុយរាប់លានដុល្លាបានចំណាយមកក្នុងប្រទេសនេះតាមរយៈសកម្មភាពជួយសង្គ្រោះ និងអភិវឌ្ឍបែបផ្សេងៗ ។ ទោះបីយ៉ាងណាក៏ដោយ យើងមិនបានមើលឃើញការប្រោសឱ្យជាច្រើនទេ ។ យើងគឺជាមនុស្សដែលខ្ទេចខ្ទាំ ។ មនុស្សដែលខ្ទេចខ្ទាំប្រឹងប្រែងខ្លាំងយ៉ាងណាក៏ដោយ ក៏មិនអាចនាំមកនូវការប្រោសឱ្យជាបានដែរ លើកលែងតែយើងប្រឹងប្រែងដោយពឹងអាងលើព្រះជាម្ចាស់ និងស្របតាមទស្សនៈវិស័យនៅក្នុងព្រះគម្ពីរ ។

ការសន្មត់មួយផ្សេងទៀតគឺថា ***ការប្រោសឱ្យជារបស់យើងមកតាមរយៈជំនឿ និងការស្ដាប់បង្គាប់*** ទាក់ទងនឹងរបៀបដែលព្រះអង្គត្រាស់ហៅយើងឱ្យរស់នៅ ។ គំនិតសុក្រឹតខាងលោកិយគិតថា ប្រសិនបើយើងគ្រាន់តែចេះវិធីជួសជុល អ្វីៗនឹងបានជា មានន័យថាឱ្យយើងប្រើប្រាជ្ញាវាងវៃបំផុត ចំណេះដឹង លុយ និងបច្ចេកវិទ្យារបស់យើង ។ ប៉ុន្តែព្រះបន្ទូលរបស់ព្រះជាម្ចាស់ផ្ទុយនឹងរបៀបគិតបែបនេះ ។ នៅក្នុ ២ របាក្សត្រ ៧:១៤ ចែងថា " បើរាស្ត្រអញដែលបានហៅតាមឈ្មោះអញ គេបន្ទាបខ្លួន ហើយអធិស្ឋានរកមុខអញ ព្រមទាំងងាកបែរចេញពីផ្លូវអាក្រក់របស់គេ នោះអញនឹងស្ដាប់ពីលើស្ថានសួគ៌ ហើយនឹងអត់ទោសអំពើបាបរបស់គេ ទាំងមើលស្រុកគេឱ្យជាផង" ។ ការប្រោសឱ្យជានឹងកើតឡើង នៅពេលដែលព្រះជាម្ចាស់អន្តរាគមន៍យ៉ាងអស្ចារ្យមកក្នុងជីវិតរបស់យើង សង្គមរបស់យើង និងប្រវត្តិសាស្ត្រ ហើយព្រះអង្គនាំមកនូវការប្រោសឱ្យជា ។ នោះមិនមានន័យថា ព្រះជាម្ចាស់នឹងមិនប្រើយើង និងការស្ដាប់បង្គាប់របស់

យើងដល់ព្រះអង្គនៅក្នុងផែនការរបស់ព្រះអង្គសម្រាប់ការប្រោសឱ្យជានោះទេ។ ព្រះជាម្ចាស់ប្រើរូបអង្គទ្រង់ដែលព្រះអង្គបានដាក់នៅក្នុងយើង ប៉ុន្តែរូបអង្គដែលគ្មានព្រះជាម្ចាស់មិនផ្ដល់ការប្រោសឱ្យជាទេ។

ការសន្និដ្ឋានបន្ទាប់មកទៀតនោះគឺថា ***ព្រះគម្ពីរគឺជាការបើកសំដែងរបស់ព្រះជាម្ចាស់សម្រាប់ការប្រោសឱ្យជារបស់យើង។*** សូមគិតថាព្រះគម្ពីរជាសៀវភៅណែនាំរបស់អ្នកផលិត។ គ្រប់របស់ប្រើប្រាស់ថ្មីដែលយើងទិញ តែងតែភ្ជាប់មកជាមួយនូវសៀវភៅណែនាំមួយក្បាល ដែលពណ៌នាអំពីរបៀបប្រើរបស់នោះ។ សៀវភៅនេះសរសេរឡើងដោយក្រុមហ៊ុនដែលផលិត ពីព្រោះក្រុមហ៊ុនដឹងរបៀបដែលរបស់នោះត្រូវបានបង្កើតឡើង និងរបៀបប្រើរបស់នោះដើម្បីទទួលបានផលប្រយោជន៍ធំធេងបំផុតពីរបស់នោះ។ ព្រះជាម្ចាស់គឺជាអ្នកបង្កើតយើង ហើយព្រះអង្គដឹងអ្វីដែលយើងត្រូវធ្វើដើម្បីរស់នៅឱ្យបានល្អ។ យើងត្រូវរស់នៅតាមរបៀបដែលព្រះអង្គត្រាស់ហៅយើងឱ្យរស់នៅ ស្វែងរកព្រះភក្ត្ររបស់ព្រះអង្គ បន្ទាបខ្លួន ហើយគិតថា ប្រាជ្ញារបស់យើងមិនបានប្រោសយើងឱ្យជាទេ ប៉ុន្តែគឺជាព្រះជាម្ចាស់ដែលប្រោសយើងឱ្យជា។ ការប្រោសយើងឱ្យជាកើតឡើង នៅពេលដែលយើងស្វែងរកការណែនាំរបស់ព្រះអង្គសម្រាប់របៀបដែលយើងត្រូវរស់នៅ និងនៅពេលដែលយើងចាប់ផ្ដើមធ្វើតាមការណែនាំទាំងនោះ។

ការសន្និដ្ឋានចុងក្រោយគឺថា ***យើងត្រូវបានបង្កើតមកដោយមានគោលបំណង។*** យើងត្រូវបានបង្កើតមក ដើម្បីស្គាល់ព្រះជាម្ចាស់។ ដំបូងបង្អស់ យើងត្រូវស្គាល់ថា ព្រះអង្គគឺជានរណា។ យើងត្រូវបានបង្កើតមកដើម្បីឱ្យបានដូចជាព្រះអង្គ។ យើងត្រូវបានបង្កើតមកដើម្បីគ្រប់គ្រងរបស់សព្វសារពើ។ តើយើងសម្រេចគោលបំណងនេះយ៉ាងដូចម្ដេច? យើងបម្រើ។ ព្រះជាម្ចាស់របស់យើងគឺជាព្រះដែលបម្រើ។ យើងត្រូវត្រាប់តាមរូបអង្គទ្រង់ជាអ្នកបម្រើ ហើយប្រសិនបើយើងមិនស្គាល់ព្រះអង្គទេ យើងនឹងបម្រើមិនដូចជាព្រះអង្គបម្រើឡើយ។ ព្រះអង្គបានបង្គាប់យើងឱ្យបម្រើ ហើយការគ្រប់គ្រងស្នាព្រះហស្តរបស់ព្រះជាម្ចាស់មានន័យបែបនោះ។ យើងគឺជាភ្នាក់ងារផ្សះផ្សាដល់ពិភពលោកដែលខ្ទេចខ្ទាំ។

## ព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់

ដើម្បីបម្រើដូចព្រះជាម្ចាស់បម្រើ យើងត្រូវយកចិត្តទុកដាក់នឹងអ្វីដែលព្រះអង្គយកព្រះហឫទ័យទុកដាក់។ យើងមានទំនោរគិតថា ព្រះអង្គយកព្រះហឫទ័យទុកដាក់ជាចម្បងទៅលើបញ្ហាខាងវិញ្ញាណ ដូចជាការប្រោសលោះមនុស្សជាដើម។ តើមិនមែនដូច្នោះទេឬ? កណ្ឌគម្ពីរលោកុប្បត្តិបង្ហាញរូបភាពធំជាងឆ្ងាយណាស់។ ជំពូក ១ បង្ហាញថាព្រះជាម្ចាស់បានយកព្រះហឫទ័យទុកដាក់នឹងវាយតម្លៃ ហើយឱ្យប្រាកដថា ស្នាព្រះហស្តរបស់ព្រះអង្គ "ល្អប្រពៃ" (១:៣១)។ ព្រះអង្គបានវាយតម្លៃភាពល្អនៃរបស់ដែលព្រះអង្គបានបង្កើត។ ព្រះអង្គបានតាំងសញ្ញាជាមួយ**<u>គ្រប់ទាំង</u>**

**ជីវិត** មិនមែនគ្រាន់តែជាមួយណូអេ និងគ្រួសាររបស់គាត់ ឬជាមួយមនុស្សជាតិតែប៉ុណ្ណោះទេ (៩:៩-១៧)។ ព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់ចំពោះជំនាន់ខាងមុខ (៦:១៨, ១៧:២-៨)។ ហើយនៅក្នុងសញ្ញាចាស់ និងសញ្ញាថ្មីទាំងមូល មានការលើកឡើងម្តងហើយម្តងទៀតអំពីព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ចំពោះ**គ្រប់ទាំងសាសន៍** មិនមែនចំពោះតែសាសន៍អ៊ីស្រាអែលមួយប៉ុណ្ណោះទេ។ តាមពិតទៅ ពាក្យ "គ្រប់ទាំងសាសន៍" មានជាងពីរពាន់ដងនៅក្នុងព្រះគម្ពីរ (លោកុប្បត្តិ ២២:១៨, ចោទិយកថា ៤:៥-៨, ២របាក្សត្រ ៧:១៤, ទំនុកដំកើង ២:៨, អេសាយ ៥៥:៣-៥, យ៉ូណាស ៣:៨-៤:២, អេសេគាល ២០ និង៣៦, លូកា ២៤:៤៧, ម៉ាថាយ ២៨:១៩, កិច្ចការ ១០:៣៤-៣៥ និង វិវរណៈ ២១:២៤ និងនៅមានខយោងជាច្រើនទៀត)។ ព្រះជាម្ចាស់ពិតជាយកព្រះហឫទ័យទុកដាក់ដល់**ស្នាព្រះហស្តទាំងអស់**ដែលព្រះអង្គបានបង្កើត រួមបញ្ចូល**គ្រប់ទាំងសាសន៍** មិនមែនដល់តែព្រលឹងរបស់យើងប៉ុណ្ណោះទេ។

ពួកយើងជាច្រើននាក់ធ្លាប់តែឮថា ព្រះយេស៊ូវបានសោយទិវង្គតដើម្បីជួយសង្គ្រោះយើង។ ប្រសិនបើព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់ចំពោះស្នាព្រះហស្តទាំងអស់ដែលព្រះអង្គបានបង្កើត តើនោះអាចមានន័យថា ការសោយទិវង្គតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាងមិនមែនសម្រាប់តែព្រលឹងរបស់យើងប៉ុណ្ណោះទេឬ? "ទ្រង់ (ព្រះគ្រីស្ទ) ជារូបអង្គនៃព្រះដ៏មើលមិនឃើញ ជាបងច្បងនៃគ្រប់ទាំងអស់ ដែលព្រះបានបង្កើតមក ដ្បិតគឺទ្រង់ហើយដែលបង្កើតគ្រប់ទាំងអស់ ទាំងរបស់នៅស្ថានសួគ៌ និងនៅផែនដី ទាំងរបស់ដែលមើលឃើញ ហើយដែលមើលមិនឃើញផង ទោះបើជារាជ្យ ឬអំណាចជាព្រះអម្ចាស់ ឬអំណាចគ្រប់គ្រង ឬអំណាចណាក៏ដោយ នោះសុទ្ធតែកើតមកដោយសារទ្រង់ ហើយសំរាប់ទ្រង់ទាំងអស់ផង" (កូល៉ុស ១:១៥-១៦)។ ហេតុអ្វីបានជាព្រះយេស៊ូវបានកំចាយព្រះលោហិតរបស់ព្រះអង្គ? "ឱ្យបានផ្សះផ្សា**គ្រប់ទាំងអស់**ឱ្យជានឹងអង្គទ្រង់ ដោយសារព្រះរាជបុត្រានោះ ទោះបើរបស់នៅស្ថានសួគ៌ ឬនៅផែនដីក្តី ទាំងតាំងស្ពានមេត្រី ដោយសារព្រះលោហិតនៃឈើឆ្កាងទ្រង់" (កូល៉ុស ១:២០)។ ព្រះយេស៊ូវបានកំចាយព្រះលោហិតសម្រាប់ប្រោសលោះ**គ្រប់ទាំងអស់**ដែលបានបាក់បែកខ្ទេចខ្ទាំនៅក្នុងការធ្លាក់ចុះ។

## ពួកជំនុំ និងការប្រោសលោះរបស់ព្រះជាម្ចាស់

យើងបានរៀនអំពីព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ចំពោះស្នាព្រះហស្តទាំងអស់ដែលទ្រង់បានបង្កើត និងការលះបង់សោយទិវង្គតរបស់ព្រះយេស៊ូវដើម្បីប្រោសលោះគ្រប់ទាំងអស់។ ដូច្នេះ តើពួកជំនុំត្រូវនៅត្រង់កន្លែងណា? "ហើយទ្រង់បានបង្ក្រាបគ្រប់ទាំងអស់នៅក្រោមព្រះបាទនៃព្រះរាជបុត្រា ទាំងប្រទានទ្រង់មកធ្វើជាសិរសាលើគ្រប់ទាំងអស់**ដល់ពួកជំនុំ**ដែលជារូបកាយទ្រង់" (អេភេសូរ ១:២២-២៣)។ តើនោះមានន័យយ៉ាងដូចម្តេច? តើព្រះជាម្ចាស់បានតែងតាំងព្រះគ្រីស្ទឱ្យធ្វើជាសិរសាលើគ្រប់ទាំងអស់ដល់ពួកជំនុំឬ? ហេតុអ្វីបានជាព្រះជាម្ចាស់

បង្ក្រាបគ្រប់ទាំងអស់ឱ្យនៅក្រោមព្រះគ្រីស្ទដល់ពួកជំនុំ " ដែលជារូបកាយទ្រង់ គឺជាសេចក្ដីពោរពេញរបស់ព្រះអង្គ ដែលបំពេញគ្រប់ទាំងអស់ ក្នុងទាំងអស់"។ នៅត្រង់នេះ លោកប៉ុលកំពុងតែនិយាយថា ពួកជំនុំគឺជារូបកាយរបស់ព្រះគ្រីស្ទ ហើយពួកជំនុំមានសក្ដានុពលនឹងបង្ហាញចេញពីសេចក្ដីពោរពេញរបស់ព្រះគ្រីស្ទ។ ពួកជំនុំមិនបង្ហាញចេញសេចក្ដីពោរពេញរបស់ព្រះគ្រីស្ទជានិច្ចកាលទេ ប៉ុន្តែពួកជំនុំមានសក្ដានុពលនឹងធ្វើបាន។ យើងកំពុងចាប់ផ្ដើមយល់អំពីអត្ថន័យដែលព្រះជាម្ចាស់បានបង្ក្រាបគ្រប់ទាំងអស់ឱ្យនៅក្រោមព្រះគ្រីស្ទដល់ពួកជំនុំ ប៉ុន្តែយើងមិនទាន់បានឃើញហេតុការណ៍នោះកើតឡើងនៅឡើយទេ។

សូមមើលនៅក្នុងអេភេសូរ ៣:១៧ ដោយយកចិត្តទុកដាក់នឹងពាក្យ "ខ្ញុំលុតជង្គង់ឱ្យព្រះគ្រីស្ទបានសណ្ឋិតក្នុងចិត្តអ្នករាល់គ្នាដោយសារសេចក្ដីជំនឿ ប្រយោជន៍ឱ្យអ្នករាល់គ្នាបានចាក់ឫស ហើយតាំងមាំមួនក្នុង**<u>សេចក្ដីស្រឡាញ់</u>** ដើម្បីឱ្យអាចនឹងយល់ជាមួយនឹងពួកបរិសុទ្ធទាំងអស់គ្នាពីទទឹង បណ្ដោយ ជំរៅ និងកំពស់នៃ**<u>សេចក្ដីស្រឡាញ់</u>**នោះ ហើយឱ្យបានស្គាល់**<u>សេចក្ដីស្រឡាញ់</u>**របស់ព្រះគ្រីស្ទដ៏រកគិតមិនយល់ ប្រយោជន៍ឱ្យអ្នករាល់គ្នាបានពេញដល់គ្រប់ទាំងសេចក្ដីពោរពេញរបស់ផងព្រះ"។

លោកប៉ុលកំពុងតែនិយាយថា សេចក្ដីពោរពេញរបស់ព្រះជាម្ចាស់ និងព្រះគ្រីស្ទគឺជាសេចក្ដីស្រលាញ់។ ប្រសិនបើលោកអ្នកចង់រកឃើញសេចក្ដីពោរពេញរបស់ព្រះជាម្ចាស់ និងសេចក្ដីពោរពេញរបស់ព្រះគ្រីស្ទដែលមិនចេះប្រែប្រួលបន្តិចសោះ នោះគឺជាសេចក្ដីស្រលាញ់ ដែលខ្ពស់ណាស់ ជ្រៅណាស់ ទទឹង និងបណ្ដោយវែងណាស់។ សេចក្ដីស្រលាញ់ដ៏ធំធេងនេះរួមមានរបៀបវារៈដ៏ធំធេងបង្ហាញពីសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ចំពោះគ្រប់ទាំងអស់ដែលព្រះអង្គបានបង្កើត។ សេចក្ដីស្រលាញ់គឺជាសេចក្ដីពោរពេញរបស់ព្រះជាម្ចាស់។ ហើយពួកជំនុំមានសក្ដានុពលនឹងបង្ហាញចេញសេចក្ដីពោរពេញនេះ ដោយព្រោះពួកជំនុំគឺជារូបកាយរបស់ព្រះគ្រីស្ទ។ យើងនឹងមើលឃើញពីរបៀបដែលសេចក្ដីនេះអាចកើតឡើងបាននៅក្នុងអេភេសូរ ៤។

ឥឡូវនេះ សូមអានអេភេសូរ ៤:១១ "ហើយទ្រង់ (ព្រះគ្រីស្ទ) បានប្រទានឱ្យអ្នកខ្លះបានធ្វើជាសាវ័ក ខ្លះជាគ្រូអធិប្បាយ ខ្លះជាគ្រូផ្សាយដំណឹងល្អ ខ្លះជាគ្រូគង្វាល ហើយខ្លះជាគ្រូបង្រៀន"។ អ្នកដឹកនាំទាំងអស់នៅក្នុងពួកជំនុំត្រូវបានកត់ត្រានៅត្រង់នេះៈ សាវ័ក គ្រូអធិប្បាយ អ្នកផ្សាយដំណឹងល្អ គ្រូគង្វាល និងគ្រូបង្រៀន។ តើតួនាទីទាំងនេះសម្រាប់អ្វីដែរ? "ប្រយោជន៍នឹងនាំឱ្យពួកបរិសុទ្ធបានគ្រប់លក្ខណ៍ឡើង សំរាប់ធ្វើការជំនួយ"។ នោះគឺជាគោលបំណងចុងក្រោយពិតប្រាកដ។ យើងត្រូវបានបង្កើតឡើងដោយមានគោលបំណង គឺដើម្បីបម្រើ។ គោលបំណងចុងក្រោយពិតប្រាកដសម្រាប់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដែលជារូបកាយរបស់ព្រះគ្រីស្ទ គឺបម្រើ។ យើងបង្ហាញចេញសេចក្ដីពោរពេញរបស់ព្រះគ្រីស្ទ តាមរយៈការបម្រើដោយសេចក្ដីស្រលាញ់។ ខ ១២-១៣ "ហើយនឹងស្អាងរូប

កាយព្រះគ្រីស្ទឡើង ទាល់តែយើងរាល់គ្នាបានរួបរួមខាងឯសេចក្ដីជំនឿរួចជាស្រេច ហើយបានស្គាល់ព្រះរាជបុត្រានៃព្រះដូចគ្នាទាំងអស់ គឺដល់បានពេញជាមនុស្ស ហើយដល់ខ្នាតកំពស់នៃសេចក្ដីពោរពេញផងព្រះគ្រីស្ទ"។ នៅត្រង់នេះព្រះជាម្ចាស់បើកសំដែងប្រាប់យើងថា ការរួបរួមគ្នានៅក្នុងរូបកាយរបស់ព្រះគ្រីស្ទកើតឡើងតាមរយៈការចូលមកជាមួយគ្នាបង្ហាញចេញសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់តាមរយៈការបម្រើ ជាជាងតាមរយៈការព្យាយាមឯកភាពគ្នាលើគោលលទ្ធិ។ នៅពេលដែលយើងចាប់ផ្ដើមធ្វើការរួមគ្នាដោយមិនគិតអំពីការខុសប្លែកគ្នា យើងអាចនិយាយគ្នាបានជាមនុស្សដែលមានគោលបំណងតែមួយ។ នៅពេលដែលយើងធ្វើកិច្ចការបម្រើដែលព្រះជាម្ចាស់បានត្រាស់ហៅយើងឱ្យធ្វើ នោះមានការរួបរួមគ្នា ហើយយើងបង្ហាញចេញសេចក្ដីពោរពេញរបស់ព្រះគ្រីស្ទ គឺជាសេចក្ដីស្រលាញ់។ អេភេសូរ ៣:១០ បរប្រយោគថា "នៅពេលឥឡូវនេះហើយ ដែលព្រះជាម្ចាស់បានជ្រើសរើសបង្ហាញចេញប្រាជ្ញាដ៏មានជាច្រើនយ៉ាងរបស់ព្រះអង្គតាមរយៈពួកជំនុំឱ្យពួកគ្រប់គ្រង និងពួកមានអំណាចនៅស្ថានដ៏ខ្ពស់បានឃើញ"។

រឿងបន្ទាប់ទៀតនេះពន្យល់ប្រាប់ខគម្ពីរទាំងនេះ។ ឧទាហរណ៍ថា មានពហុកីឡាដ្ឋានបាល់ទាត់មួយដែលមានមនុស្សពេញ កំពុងទស្សនាបាល់ទាត់។ មានអ្នកអង្គុយមើលយ៉ាងណែនណាន់។ អ្នកទស្សនាទាំងនេះតំណាងឱ្យពួកគ្រប់គ្រង និងពួកមានអំណាចនៅស្ថានដ៏ខ្ពស់។ នៅលើទីលានបាល់ទាត់ មានកីឡាករពីរក្រុម គឺនគរនៃសេចក្ដីងងឹត និងពួកជំនុំ។ ក្រុមនិមួយៗមានគ្រូបង្វឹក។ គ្រូបង្វឹករបស់នគរនៃសេចក្ដីងងឹតគឺជាអារក្សសាតាំង ហើយគ្រូបង្វឹករបស់នគរនៃពន្លឺ ឬពួកជំនុំគឺជាព្រះយេស៊ូវគ្រីស្ទ។ ព្រះយេស៊ូវដែលជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់មានផែនការយុទ្ធសាស្ត្រដែលព្រះអង្គចង់ឱ្យក្រុមកីឡាកររបស់ព្រះអង្គធ្វើតាម។ នៅពេលដែលពួកគេស្ដាប់តាមគ្រូបង្វឹករបស់ពួកគេ ពួកគេឈ្នះបានពានដ៏នៅអស់កល្បជានិច្ច មិនមែនពានរបស់លោកិយនេះទេ។ ពាននេះធំជាងពានរបស់លោកិយឆ្ងាយណាស់។ នេះគឺជាពានដែលនៅអស់កល្បជានិច្ច។ មានតែនៅពេលដែលពួកជំនុំធ្វើតាមផែនការយុទ្ធសាស្ត្រប៉ុណ្ណោះ ទើបទាត់បាល់ចូលទីហើយឈ្នះការប្រកួត។ ប្រសិនបើយើងអានបទគម្ពីរនេះតទៅទៀត យើងឃើញថា ពួកគ្រប់គ្រង និងពួកមានអំណាចនៅស្ថានដ៏ខ្ពស់មិនមែនល្អទេ។ ពួកវាមិនមែនជាទេវតាដែលនៅស្ថានសួគ៌ឡើយ ពួកវាគឺជាបរិវាររបស់អារក្សសាតាំង។ ព្រះជាម្ចាស់ចង់បង្ហាញប្រាប់អារក្សសាតាំង និងពួកមានអំណាចនៅក្នុងនគរនៃសេចក្ដីងងឹតថា ព្រះអង្គនឹងប្រោសលោះរបស់ទាំងអស់ដែលបានបាក់បែកតាមរយៈផែនការដ៏មានជាច្រើនយ៉ាងរបស់ព្រះអង្គ។ ផែនការនោះមិនមែនមានតែមួយយ៉ាងសម្រាប់តែសេចក្ដីសង្គ្រោះខាងវិញ្ញាណប៉ុណ្ណោះទេ។ ផែនការនោះមានជាច្រើនយ៉ាងវិញ។ ផែនការនោះគឺជារបៀបវារៈដែលរួមមានការស្ដារឡើងវិងគ្រប់ទាំងអស់ដែលបានបាក់បែកនៅក្នុងការធ្លាក់ចុះ។ ហើយនៅពេលដែលពួកជំនុំស្ដាប់បង្គាប់តាមការណែនាំរបស់ព្រះគ្រីស្ទអំពីរបៀបដែលយើងត្រូវរស់នៅក្នុងលោកិយ នោះយើងមើលឃើញគោលបំណងដ៏ធំរបស់ព្រះជាម្ចាស់បានសម្រេច គឺការប្រោសលោះគ្រប់ទាំងអស់ដែលបានបាក់បែក។

## ពួកជំនុំមានច្រើន ការបំផ្លាស់បំប្រែមានតិចតួច

មានសម័យកាលផ្សេងៗគ្នានៅក្នុងប្រវត្តិសាស្ត្រ ដែលព្រះជាម្ចាស់បានប្រើពួកជំនុំដើម្បីបំផ្លាស់បំប្រែសង្គម។ ឧទាហរណ៍មួយក្នុងចំណោមឧទាហរណ៍ពញ្ញាក់អារម្មណ៍ខ្លាំងបំផុត មាននៅក្នុងសៀវភៅដែលមានចំណងជើងថា ការងើបឡើងរបស់គ្រីស្ទបរិស័ទ និពន្ធដោយអ្នកវិទ្យាសាស្ត្រសង្គមម្នាក់ឈ្មោះ រ៉ូឌនី ស្តាក។ លោក ស្តាក ចង់ដឹងអំពីកត្តាដែលបានបណ្តាលឱ្យចក្រភពរ៉ូមផ្លាស់ប្តូរពីចក្រភពដែលមិនកាន់ជំនឿគ្រីស្ទបរិស័ទមកជាចក្រភពកាន់ជំនឿគ្រីស្ទបរិស័ទវិញ ដែលនោះគឺជាការផ្លាស់ប្តូរយ៉ាងធំធេងបំផុតនៅក្នុងសង្គម មិនធ្លាប់កើតមាននៅក្នុងប្រវត្តិសាស្ត្រលោកខាងលិចពីរពាន់ឆ្នាំមកហើយ។ គាត់បានសួរអំពីរបៀបដែលមនុស្សមួយក្រុមតូចមានគ្នា ១២០ នាក់ ដែលត្រូវគេបៀតបៀនបដិសេធ គាបសង្កត់ និងប្រមាថមើលងាយនៅក្នុងកិច្ចការ ១:១៤ អាចបំផ្លាស់បំប្រែចក្រភពរ៉ូមដ៏មានអំណាចនៅក្នុងរយៈពេល ៣០០ឆ្នាំបាន។ គាត់បានរកឃើញប្រព័ន្ធជំនឿមួយ ដែលបាននាំមកនូវនិមិត្តថ្មីអំពីមនុស្សជាតិ។ គាត់ជឿថាជំនឿទាំងនេះគឺជាកត្តាគ្រឹះដែលនាំឱ្យមានការផ្លាស់ប្តូរសង្គមនេះ។

១. ជាលើកដំបូងហើយនៅក្នុងពិភពលោកដែលមិនកាន់ជំនឿគ្រីស្ទបរិស័ទ មានជំនឿជឿថា មានព្រះដែលស្រលាញ់អ្នកដែលស្រលាញ់ព្រះអង្គ។ នៅក្នុងចក្រភពរ៉ូម ព្រះមិនបានស្រលាញ់អ្នកដែលថ្វាយបង្គំខ្លួនទេ ហើយសូម្បីតែព្រះ ក៏ប្រយុទ្ធគ្នាទៅវិញទៅមកដែរ។ ព្រះទាំងនោះមិនយកព្រះហឫទ័យទុកដាក់ចំពោះមនុស្សដែលថ្វាយបង្គំខ្លួនទេ។ ប៉ុន្តែជាលើកដំបូងហើយនៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សដែលឮថា មានព្រះដែលស្រលាញ់អ្នកដែលស្រលាញ់ព្រះអង្គ។ មិនត្រឹមតែប៉ុណ្ណោះទេ ព្រះអង្គបានតម្រូវឱ្យអ្នកដែលស្រលាញ់ព្រះអង្គ ស្រលាញ់ដល់អ្នកដទៃទៀតដែរ។

២. ជំនឿសំខាន់ទីពីរគឺថា ព្រះដ៏មានសេចក្តីមេត្តាករុណាដែលតម្រូវឱ្យមានសេចក្តីមេត្តាករុណា។ ម្តងទៀតនេះផ្ទុយនឹងជំនឿសាសនានៅក្នុងចក្រភពរ៉ូម។ រ៉ូមល្បីល្បាញដោយព្រោះតែភាពព្រៃផ្សៃរបស់ខ្លួន។ លោក ស្តាក ផ្តល់ឱ្យយើងនូវឧទាហរណ៍មួយអំពីព្រះចៅអធិរាជមួយអង្គបានឱ្យទាសករវាយសម្លាប់គ្នាទៅវិញទៅមកនៅក្នុងកីឡាដ្ឋាន ដើម្បីឱ្យបុត្រារបស់ព្រះអង្គអាចមើលឃើញឈាមហូរដល់ស្លាប់ ដើម្បីជាការអបអរភាពពេញវ័យរបស់ព្រះបុត្រានោះ។ អ្នកនិពន្ធជនជាតិរ៉ូមជាច្រើនបានសើចចំអកឱ្យគ្រីស្ទបរិស័ទ ពីព្រោះពួកគេមានសេចក្តីមេត្តាករុណា ជាពិសេសចំពោះអ្នកក្រ។ នេះគឺជារឿងកំប្លែងមួយសម្រាប់អ្នកនិពន្ធជនជាតិរ៉ូមជាច្រើននៅសម័យដើម។ ហេតុអ្វីបានជាអ្នកយកចិត្តទុកដាក់ចំពោះអ្នកក្រ? ប៉ុន្តែនេះគឺជាជំនឿដ៏សំខាន់មួយរបស់សាសនាថ្មីនេះ។

៣. ជំនឿដ៏សំខាន់មួយផ្សេងទៀតគឺថា វប្បធម៌មិនគួរតែគ្មានជាតិសាសន៍ និងវណ្ណៈ។ ម្តងទៀត អ្នកនៅរ៉ូមគិតថា គំនិតនេះឆ្កួតលេលា គួរឱ្យចង់សើច និងមិនសមហេតុផលទាល់តែសោះ។ នៅក្នុងការថ្វាយបង្គំរបស់គ្រីស្ទបរិស័ទ អភិជន និងទាសករមកថ្វាយបង្គំព្រះជាម្ចាស់ជាមួយគ្នា ដូចជាបងប្អូន។ គួរឱ្យអស់សំណើចខ្លាំងណាស់! ហេតុអ្វីបានជាអភិជនអនុញ្ញាតឱ្យទាសករហៅគាត់ថាជាបងប្អូន? ហើយអភិជនហៅទាសករនោះថាជាបងប្អូនដូច្នេះ? នេះគឺជានិមិត្តថ្មីអំពីមនុស្សជាតិ។

៤. គំនិតដែលលេលាមួយផ្សេងទៀតគឺថា មនុស្សប្រុសត្រូវស្រលាញ់ប្រពន្ធដូចខ្លួនឯង។ គ្រប់គ្នាដឹងថា មនុស្សប្រុសលើសជាងមនុស្សស្រី! បុរសជនជាតិរ៉ូមជាម្ចាស់លើប្រពន្ធ និងកូនរបស់ពួកគេ។ លោក ស្តាក បាននិយាយថា បុរសជនជាតិរ៉ូមអាចសម្លាប់កូនរបស់ពួកគេបាន ដោយគ្មានទោសតាមផ្លូវច្បាប់ទេ ពីព្រោះកូនគឺជាទ្រព្យសម្បត្តិរបស់ពួកគេ ហើយពួកគេអាចធ្វើអ្វីបានតាមចិត្តជាមួយនឹងទ្រព្យសម្បត្តិរបស់ពួកគេ។ ប៉ុន្តែនៅក្នុងសាសនាថ្មីនេះ អ្នកត្រូវស្រលាញ់ប្រពន្ធកូនរបស់អ្នកដូចខ្លួនឯង។

៥. គ្រីស្ទបរិស័ទមួយក្រុមនេះក៏បានបដិសេធការរំលូតកូន និងការសំលាប់ទារកផងដែរ។ លោក ស្តាក បានដកស្រង់ចេញពីសំបុត្រមួយច្បាប់ដែលសរសេរឡើងដោយទាហានរ៉ូមម្នាក់ទើបតែរៀបការ និងកំពុងចេញដំណើរទៅច្បាំង។ គាត់បានសរសេរសំបុត្រនេះផ្ញើទៅឱ្យប្រពន្ធរបស់គាត់នៅឯផ្ទះ ដោយនិយាយថា "អូនសម្លាញ់ បងនឹកអូនខ្លាំងណាស់។ បងសប្បាយចិត្តណាស់ ពេលដឹងថា អូនមានផ្ទៃពោះ"។ គាត់បាននិយាយតទៅទៀតថា "ប្រសិនបើជាកូនប្រុស សូមមើលថែចិញ្ចឹមវាឱ្យល្អ ប្រសិនបើជាកូនស្រីវិញ ទុកចោលឱ្យស្លាប់ទៅ"។ សំបុត្រនេះធម្មតានៅសម័យនោះ។ ប៉ុន្តែនៅក្នុងសាសនាថ្មីនេះ ជីវិតទាំងអស់មានតម្លៃ ទោះជាកើតមកពិការ ឬមិនទាន់កើត ឬជាប្រុស ជាស្រី ឬជាទាសករ ឬជាវណ្ណៈអភិជនក៏ដោយ។

៦. ឧទាហរណ៍ចុងក្រោយដែលលោក ស្តាក ផ្តល់ឱ្យ គឺរបៀបដែលគ្រីស្ទបរិស័ទទាំងនេះស្រលាញ់មនុស្ស ទោះជាគ្រីស្ទបរិស័ទ ឬមិនមែនជាគ្រីស្ទបរិស័ទក៏ដោយ ជាពិសេសនៅក្នុងពេលដែលឈឺ។ ការរស់នៅក្នុងក្រុងរ៉ូម យើងប្រហែលជាគិតថា សុទ្ធតែរុងរឿងហើយ។

គ្រីស្ទបរិស័ទសង្កត់ធ្ងន់លើសេចក្តីស្រលាញ់ និងសប្បុរសធម៌ជាភារកិច្ចសំខាន់នៅក្នុងជំនឿ។ នៅក្នុងពេលដែលមានជម្ងឺឆ្លង តើនឹងមានការខុសប្លែកអ្វី ប្រសិបើគ្រីស្ទបរិស័ទបង្ហាញចិត្តមេត្តាករុណា និងសប្បុរសធម៌? គួរឱ្យភ្ញាក់ផ្អើលណាស់ ឱកាសរស់របស់មនុស្សបានល្អប្រសើរឡើងយ៉ាងខ្លាំងតាមរយៈការយកចិត្តទុកដាក់ដ៏តូចតាចដែលគ្រីស្ទបរិស័ទបានផ្តល់ឱ្យ។ ពេទ្យជនជាតិរ៉ូមគ្មានហេតុផលនឹងបម្រើអ្នកឈឺទេ ហើយជាញឹកញាប់ បាត់រត់ចេញពីទីក្រុងដែលមានជម្ងឺឆ្លង។ អ្នកផ្សេងទៀតដែលមិនអាចរត់គេច បាន

ជាញឹកញាប់បានយកអ្នកឈឺទៅខាងក្រៅដាក់ចោលនៅតាមផ្លូវ ដោយខ្លាចឆ្លង។ គ្រីស្ទបរិស័ទមិនត្រឹមតែយកចិត្តទុកដាក់ចំពោះខ្លួនឯងប៉ុណ្ណោះទេ ថែមទាំងយកចិត្តទុកដាក់ចំពោះអ្នកដទៃទៀតផង។ លទ្ធផលកើតមានគឺជ្រាលជ្រៅណាស់។ មនុស្សជាច្រើនបានឃើញទស្សនៈថ្មីចំពោះមនុស្សចេញពីជំនឿគ្រីស្ទបរិស័ទ និងបានប្រែចិត្តធ្វើជាគ្រីស្ទបរិស័ទ។ នៅក្នុងឆ្នាំ ៤០ នៃគ្រីស្ទសករាជ មានអ្នកជឿតែ ១,០០០ នាក់ប៉ុណ្ណោះ ស្មើនឹង ០.០០១៧ ភាគរយនៃចំនួនមនុស្ស ៦០ លាននាក់។ លោក ស្តាក ប្រមើលមើលថា នៅត្រឹមឆ្នាំ ៣០០ នៃគ្រីស្ទសករាជ មានគ្រីស្ទបរិស័ទ ៦ លាននាក់នៅក្នុងចក្រភពរ៉ូម ស្មើនឹង ១០.៥ ភាគរយនៃចំនួនប្រជាជនសរុប។ ស្តេច ខុសស្ទិនស្តាញ បានទទួលស្គាល់ជំនឿគ្រីស្ទបរិស័ទតាមផ្លូវច្បាប់ និងបានត្រួសត្រាយផ្លូវឱ្យជំនឿគ្រីស្ទបរិស័ទបានក្លាយទៅជាសាសនារដ្ឋនៅក្នុងឆ្នាំ ៣៨១ នៃគ្រីស្ទសករាជ។ ទោះបីជាគ្រីស្ទបរិស័ទមានតែ ១០.៥ ភាគរយនៃចំនួនប្រជាជនសរុបក៏ដោយ យើងមើលឃើញការបំផ្លាស់បំប្រែសង្គម និងវប្បធម៌ទាំងមូល។

មានឧទាហរណ៍ស្រដៀងគ្នាជាច្រើននិយាយអំពីឥទ្ធិពលដ៏ធំធេងមកលើសង្គមនៅក្នុងប្រវត្តិសាស្ត្រពួកជំនុំ។ សង្គមនៅក្នុងទ្វីបអឺរ៉ុប ប្រទេសស្វ៊ីស ប្រទេសអាឡឺម៉ង់ និងប្រទេសហូឡង់ ត្រូវបានបំផ្លាស់បំប្រែនៅក្នុងអំឡុងពេលដែលមានបដិវត្តន៍គ្រីស្ទបរិស័ទ។ ប្រទេសអង់គ្លេសមានការបំផ្លាស់បំប្រែសង្គមយ៉ាងអស្ចារ្យ ពេលដែលទស្សនៈវិស័យនៅក្នុងព្រះគម្ពីរបានមកដល់ប្រទេសនេះ។ ច្បាប់ប្រឆាំងនឹងការជួញដូរទាសករ និងអំពើទាសភាពត្រូវបានអនុម័តដោយទទួលឥទ្ធិពលពីលោក វីលាម វៀលប៊ីហ្វ័ស នាំឱ្យមានការយល់ព្រមជាឯកច្ឆន្ទនៅក្នុងរដ្ឋសភា ការផុសផុលដឹកនាំដោយលោកវេស្លី និងការរីកចម្រើនច្រើនឡើងនៃក្រុមផ្សេងៗនៅក្នុងរូបកាយរបស់ព្រះគ្រីស្ទ។ មនុស្សនៅក្នុងសង្គមកំពុងតែអនុវត្តជំនឿរបស់ពួកគេតាមរបៀបថ្មីៗ។

## ហេតុអ្វីមិនមាននៅសព្វថ្ងៃនេះ

យើងអរសប្បាយចំពោះឥទ្ធិពលរបស់ពួកជំនុំមកលើប្រវត្តិសាស្ត្រ ប៉ុន្តែយើងត្រូវសួរថា ហេតុអ្វីបានជាពួកជំនុំនៅសព្វថ្ងៃនេះមិនមានឥទ្ធិពលធំធេងដូច្នោះមកលើវប្បធម៌របស់ខ្លួន។ ឧទាហរណ៍ ៤០ ភាគរយនៃចំនួនប្រជាជននៅក្នុងប្រទេសកូតម៉ាឡាប្រកាសថាជាអ្នកជឿព្រះយេស៊ូវ ប៉ុន្តែប្រទេសនេះជាប្រទេសដែលពុករលួយ និងក្រីក្រ។ តើមានអ្វីខុស? នៅក្នុងប្រទេស រវ៉ាន់ដា ៨០ ភាគរយប្រកាសថាធ្លាប់ជាគ្រីស្ទបរិស័ទមុនអំពើប្រល័យពូជសាសន៍។ សភាពនេះដូចគ្នាទាំងអស់នៅជុំវិញពិភពលោក។ តើយើងមិនគួរមើលឃើញការផ្លាស់ប្តូរយ៉ាងធំធេងនៅក្នុងសង្គមទេឬអី? នៅ

ក្នុងចក្រភពរ៉ូម គ្រីស្ទបរិស័ទតែ ១០.៥ ភាគរយនៃចំនួនប្រជាជនសរុបប៉ុណ្ណោះបានផ្លាស់ប្តូរចក្រភពទាំងមូល។ ប្រាកដជាមានអ្វីខុសហើយ។ ពួកជំនុំនៅពេលបច្ចុប្បន្ននេះមិនមានឥទ្ធិពលមកលើសង្គម តើអាចដោយព្រោះពួកជំនុំផ្តោតទៅលើតែផ្នែកមួយនៃរបៀបវារៈរបស់ព្រះជាម្ចាស់ដែរឬទេ? តើពួកជំនុំនៅពេលបច្ចុប្បន្ននេះត្រូវដឹងគ្រប់ផ្នែកទាំងអស់នៃរបៀបវារៈដ៏មានជាច្រើនយ៉ាងរបស់ព្រះជាម្ចាស់ដែរឬទេ?

ជាការសំខាន់ណាស់ដែលត្រូវយល់អំពីមូលហេតុដែលពួកជំនុំអភិរក្សជាច្រើននៅក្នុងរយៈពេល ១៥០ ឆ្នាំមកនេះ មិនបានផ្តោតលើរបៀបវារៈទាំងមូលរបស់ព្រះជាម្ចាស់។ នៅក្នុងឆ្នាំ ១៨៥០ មានចលនាទេវសាស្ត្រមួយនៅក្នុងទ្វីបអឺរ៉ុប ហៅថា ការវិភាគខ្ពស់ជាងមុន ដែលបង្កើតបានជាគោលលទ្ធិមួយ ត្រូវបានគេស្គាល់ថាជា ដំណឹងល្អដល់សង្គម។ គោលលទ្ធិមួយគឺថា នគរព្រះមកដល់ផែនដី នៅពេលដែលពួកជំនុំធ្វើកិច្ចការបម្រើ។ គោលលទ្ធិមួយផ្សេងទៀតគឺជាសាកលនិយម គឺមនុស្សទាំងអស់ត្រូវបានសង្គ្រោះ ទោះបីជាពួកគេឆ្លើយតបបែបយ៉ាងណាក៏ដោយចំពោះដំណឹងល្អ។ គោលលទ្ធិទាំងនេះខុសឆ្គងសម្រាប់ពួកជំនុំអភិរក្ស ដែលជឿថា មនុស្សម្នាក់ៗត្រូវកើតជាថ្មី។

ជាប្រតិកម្មតបតទៅវិញ ពួកជំនុំអភិរក្សបានបណ្តុះបណ្តាលគ្រូគង្វាល និងបេសកជនតែអំពីការផ្សាយដំណឹងល្អ និងការប្រែចិត្តខាងវិញ្ញាណ ដោយព្រងើយកន្តើយចំពោះផ្នែកដទៃទៀតនៃរបៀបវារៈទាំងមូលរបស់ព្រះជាម្ចាស់។ បន្ទាប់មក បេសកជនទាំងនេះបានបង្រៀនជំនាន់ក្រោយៗទៀតដោយមានផ្នត់គំនិតនោះ ដែលមិនដាក់បញ្ចូលរបៀបវារៈទាំងមូលរបស់ព្រះជាម្ចាស់ទេ។ សូម្បីតែនៅសព្វថ្ងៃនេះ អ្នកជឿជាច្រើនក្រុមនៅជុំវិញពិភពលោកនៅតែមានទស្សនៈវិស័យតូចចង្អៀតដដែលចំពោះដំណឹងល្អ។ យើងអរព្រះគុណព្រះជាម្ចាស់សម្រាប់បេសកជន ការប្តេជ្ញាចិត្ត និងកិច្ចការដ៏អស្ចារ្យរបស់ពួកគេ ប៉ុន្តែពួកគេមិនបានដឹងថា ផ្នែកមួយនៃផែនការរបស់ព្រះជាម្ចាស់ គឺប្រើពួកជំនុំដើម្បីបំផ្លាស់បំប្រែសង្គម។

ពួកជំនុំអភិរក្សក៏បានទទួលឥទ្ធិពលពីគោលលទ្ធិមួយដែលហៅថា បោះចោលនិយម។ គោលលទ្ធិនេះត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៨៤០ និងបានបង្រៀនថា លោកិយនេះនឹងកាន់តែអាក្រក់ទៅៗ រហូតដល់ព្រះយេស៊ូវយាងត្រលប់មកវិញ ហើយចាត់ទុកនគរព្រះសម្រាប់ពេលអនាគត គឺក្រោយពេលដែលព្រះយេស៊ូវយាងត្រលប់មកវិញ។ នៅពេលដែលពួកជំនុំជឿថា នគរព្រះសម្រាប់តែពេលអនាគត ហើយជឿថា មិនអាចធ្វើអ្វីបានដើម្បីប្រោសពិភពលោកនេះឱ្យជា ពួកជំនុំគ្មានហេតុផលនឹងមានឥទ្ធិពលលើសង្គមទេ។ នោះមិនមែនជាទស្សនៈវិស័យនៅក្នុងព្រះគម្ពីរទេ។ ព្រះយេស៊ូវមានបន្ទូលថា "នគរព្រះក៏នៅកណ្តាលអ្នករាល់គ្នាហើយ"។ នគរព្រះមានទាំងនៅពេលបច្ចុប្បន្ន និងនៅពេលអនាគត។ តើព្រះយេស៊ូវបានបង្រៀនយើងឱ្យអធិស្ឋានយ៉ាងដូចម្តេច "សូមឱ្យរាជ្យទ្រង់បានមកដល់ សូមឱ្យព្រះហឫទ័យទ្រង់បានសំរេចនៅផែនដីដូចនៅស្ថានសួគ៌ដែរ"។ តើព្រះអង្គមានន័យថា ក្រោយពីព្រះអង្គយាងត្រលប់មកវិញជាលើក

ទីពីរឬ? ប្រាកដជាមិនមែនទេ។ ព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់ចង់ឱ្យបំណងព្រះហឫទ័យរបស់ព្រះអង្គបានសម្រេចនៅផែនដី ដូចជានៅស្ថានសួគ៌ដែរ។ ហើយនៅពេលដែលបំណងព្រះហឫទ័យរបស់ព្រះអង្គបានសម្រេចនៅផែនដី នោះរាជ្យទ្រង់បានមកដល់។

ពេលខ្លះ នៅពេលដែលពួកជំនុំអភិរក្សធ្វើគម្រោងជួយមនុស្សខាងសាច់ឈាម ឬជួយសង្គម ពួកគេចាត់ទុកគម្រោងទាំងនោះជាវិធីផ្សាយដំណឹងល្អតែប៉ុណ្ណោះ។ ពួកជំនុំត្រូវចងចាំថា ព្រះយេស៊ូវបានបង្ហាញសេចក្ដីស្រលាញ់ និងព្រះហឫទ័យអាណិតអាសូររបស់ព្រះអង្គដល់មនុស្សទាំងអស់ ទោះបីជាពួកគេឆ្លើយតបយ៉ាងណាក៏ដោយចំពោះព្រះអង្គ។ ព្រះអង្គបានប្រោសមនុស្សឃ្លង់ដប់នាក់ឱ្យបានជា ទោះបីជាព្រះអង្គដឹងថា ប្រាំបួននាក់នឹងមិនឆ្លើយតបក៏ដោយ។

ចាប់តាំងពីពេលដែលព្រះយេស៊ូវនៅលើផែនដីមក មនុស្សគ្រប់ជំនាន់បានជឿថា ពួកគេនៅក្នុងជំនាន់ដែលព្រះយេស៊ូវនឹងយាងត្រលប់មកវិញ។ នោះមិនមែនជាទស្សនៈវិស័យដែលអាក្រក់ទេ។ យើងត្រូវរស់នៅ ហាក់បីដូចជាព្រះគ្រីស្ទនឹងយាងត្រលប់មកវិញនៅថ្ងៃស្អែកនេះ នៅសប្ដាហ៍ក្រោយ ឬនៅឆ្នាំក្រោយ។ ប៉ុន្តែព្រះអង្គប្រហែលជាមិនទាន់យាងមកទេនៅក្នុងរយៈពេលដប់ឆ្នាំទៀត មួយរយឆ្នាំទៀត មួយពាន់ឆ្នាំទៀត។ ហើយប្រសិនបើព្រះអង្គមិនទាន់យាងមកវិញនៅក្នុងរយៈពេលនោះ តើព្រះអង្គចង់ឃើញយើងរវល់ធ្វើអ្វី? រវល់រហូតដល់ព្រះអង្គយាងត្រលប់មកវិញ! គ្មាននរណាម្នាក់ដឹងអំពីថ្ងៃ ឬពេលដែលកូនមនុស្សនឹងយាងត្រលប់មកវិញទេ មានតែព្រះវរបិតាមួយព្រះអង្គប៉ុណ្ណោះដែលដឹង។

មានបញ្ហាដទៃទៀត។ ខាងប្រវត្តិសាស្ត្រ បិតុនិយម បានបំបាក់ទឹកចិត្តពួកជំនុំនៅក្នុងប្រទេសតតិយលោកមិនឱ្យមាននិមិត្តគ្រប់ជ្រុងជ្រោយ។ បេសកជនជាច្រើនមកពីប្រទេសលោកខាងលិចមានចំណេះដឹងខ្ពស់ និងមានការយល់ដឹងបែបវិទ្យាសាស្ត្រ ព្រមទាំងបាននាំបច្ចេកវិទ្យា និងលុយមក ដោយមានបំណងចង់ជួយនាំមកនូវការប្រោសឱ្យជាខាងសាច់ឈាម និងសង្គម។ កិច្ចខិតខំប្រឹងប្រែងជាច្រើនសម្រាប់ជួយខាងសាច់ឈាម ឬសង្គម ដែលភ្នាក់ងារខាងក្រៅបានធ្វើ ឈរនៅលើជំនឿថា ម្ចាស់ស្រុកមិនអាចជួយខ្លួនពួកគេបាន ហើយកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍដោយមានបំណងល្អទាំងនោះ បានបង្កើតភាពពឹងផ្អែក និងពង្រឹងផ្នត់គំនិតជាអ្នកក្រ និងជាតានិយម។ អ្នកដែលមានធនធានខាងសាច់ឈាមមានកាតព្វកិច្ចជួយអ្នកដទៃទៀត ប៉ុន្តែត្រូវលើកទឹកចិត្តអ្នកខ្វះខាតជានិច្ចឱ្យស្វែងរក និងប្រើសក្ដានុពល និងធនធានដែលព្រះជាម្ចាស់បានប្រទានឱ្យពួកគេ។ អ្នកនៅក្នុងប្រទេសកំពុងអភិវឌ្ឍត្រូវដឹងថា ព្រះជាម្ចាស់បានដាក់ប្រាជ្ញា សមត្ថភាព ភាពឆ្នៃប្រឌិត និងរូបអង្គទ្រង់នៅក្នុងពួកគេ ដូចដែលព្រះអង្គបានប្រទានឱ្យអ្នកនៅក្នុងប្រទេសអភិវឌ្ឍដែរ។

## អំពើបាបដោយអចេតនា

ជាការសំខាន់ណាស់ដែលត្រូវយល់ថា អតុល្យភាពនេះមិនបានកើតឡើងនៅក្នុងសម័យបច្ចុប្បន្នទេ។ យើងមើលឃើញអតុល្យភាពនេះនៅក្នុងសញ្ញាចាស់។ នៅក្នុងអេសាយ ៥៨ ព្រះជាម្ចាស់កំពុងស្រែកឱ្យអ៊ីស្រាអែលយកចិត្តទុកដាក់ កែតម្រង់ការយល់ច្រលំរបស់ពួកគេអំពីរបៀបវារៈធំរបស់ព្រះអង្គ។ បួនខដំបូងនៅក្នុងអេសាយ ៥៨ បង្ហាញឱ្យឃើញយ៉ាងច្បាស់ថា ជនជាតិអ៊ីស្រាអែលបានគិតថា ពួកគេកំពុងថ្វាយបង្គំព្រះជាម្ចាស់ ដូចដែលព្រះអង្គចង់បាន ប៉ុន្តែខគម្ពីរទាំងនោះក៏បានបង្ហាញឱ្យឃើញច្បាស់ផងដែរថា តាមទស្សនៈវិស័យរបស់ព្រះជាម្ចាស់ ពួកគេមិនបានកំពុងថ្វាយបង្គំព្រះអង្គ ដូចដែលព្រះអង្គចង់បានទេ។

នៅក្នុងអេសាយ ៥៨:៣ ជនជាតិនេះបានសួរព្រះជាម្ចាស់ថា "យើងខ្ញុំបានតមអត់ ហេតុអ្វីបានជាទ្រង់មិនឃើញសោះ"។ ពួកគេបានគិតថា ពួកគេនឹងទទួលបានការសព្វព្រះហឫទ័យ និងព្រះពរពីព្រះជាម្ចាស់ តាមរយៈការតមអត់ និងការបញ្ឈឺចិត្តខ្លួន។ នៅពេលដែលពួកគេមិនឃើញសញ្ញាអំពីព្រះពររបស់ព្រះជាម្ចាស់ ពួកគេរអ៊ូរទាំ។ ព្រះជាម្ចាស់ឆ្លើយមកវិញយ៉ាងម៉ឺងម៉ាត់ថា " ការដែលឯងតមអត់នោះ គឺមិនមែនមានប្រយោជន៍ឱ្យសំឡេងឯងបានឮទៅដល់ស្ថានលើឡើយ"។ ព្រះជាម្ចាស់មិនសព្វព្រះហឫទ័យនឹងទង្វើបែបសាសនារបស់អ្នកដែលប្រព្រឹត្តដោយអយុត្តិធម៌ និងដោយគ្មានចិត្តអាណិតអាសូរនោះទេ។ ព្រះអង្គបានហៅឱ្យប្រែចិត្ត។

នៅក្នុងពាក្យកាព្យដែលមានចុងជួនដូចគ្នាបី ព្រះជាម្ចាស់ពន្យល់អំពីការថ្វាយបង្គំបែបដែលព្រះអង្គចង់បាន និងប្រាប់អំពីលទ្ធផលដែលកើតចេញពីការថ្វាយបង្គំបែបសមរម្យនោះ។ នៅក្នុងពាក្យកាព្យទីមួយ ព្រះជាម្ចាស់ប្រាប់ជនជាតិអ៊ីស្រាអែលថា ការថ្វាយបង្គំដ៏ពិតរួមមានការបម្រើដល់ភាពខ្វះខាតខាងសាច់ឈាម និងខាងសង្គមរបស់អ្នកដែលគ្មានអំណាច (ខ ៦ និង ៧) បន្ទាប់មក គឺជាសេចក្តីសន្យាប្រោសភាពខ្ទេចខ្ទាំផ្ទាល់របស់អ៊ីស្រាអែលឱ្យជា នៅពេលដែលប្រជាជនស្តាប់បង្គាប់ (ខ ៨ និង ៩)។ នៅក្នុងពាក្យកាព្យទីពីរ ព្រះជាម្ចាស់ប្រាប់ជនជាតិអ៊ីស្រាអែលថា ការថ្វាយបង្គំដ៏ពិតរួមមានការឈប់បែងចែកដ៏អាក្រក់នៅក្នុងចំណោមប្រជារាស្ត្ររបស់ព្រះអង្គ និងបញ្ជាក់ឡើងវិញថាត្រូវមើលថែអ្នកដែលគ្មានអំណាច (ខ ៩ និង ១០) បន្ទាប់មក គឺជាសេចក្តីសន្យាអំពីការប្រោសឱ្យជាតាមរយៈការពណ៌នាយ៉ាងល្អបំផុតមួយនៅក្នុងព្រះគម្ពីរ (ខ ១០ និង ១២)។ នៅក្នុងពាក្យកាព្យទីបី ព្រះជាម្ចាស់បញ្ជាក់ឡើងវិញអំពីការកាន់តាមថ្ងៃសប្ប័ទ (ខ ១៣) ប៉ុន្តែមិនមែនថាមិនបង្ហាញចេញសេចក្តីស្រលាញ់ទេ។ អ្នកដែលគោរពថ្ងៃសប្ប័ទមិនធ្វើតាមចិត្តខ្លួនឯង និងមិននិយាយ"ពាក្យឥតបានការ"ទាស់នឹងអ្នកដទៃទៀតទេ (ខ ១៣)។ បន្ទាប់មកព្រះជាម្ចាស់សន្យាថានឹងប្រទានឱ្យពួកគេមានអំណរ ការស្អាងឡើងវិញ និងមរតក (ខ ១៤)។

អេសាយ ៥៨ ផ្តល់ឱ្យនូវទស្សនៈវិស័យថ្មីអំពីការថ្វាយបង្គំខាងវិញ្ញាណ។ ការថ្វាយបង្គំមិនមែនជាការសំដែងចេញខាងក្រៅតាមច្បាប់ និងភារកិច្ចនោះទេ ប៉ុន្តែជាឥរិយាបថនៅខាងក្នុងចិត្ត ដែលចង់បម្រើព្រះជាម្ចាស់ និងមនុស្សដទៃទៀត។ អត្ថបទអេសាយ ៥៨ ហាក់បីដូចជាបង្ហាញឱ្យឃើញច្បាស់ថា អំពើបាបរបស់អ៊ីស្រាអែលចំពោះការថ្វាយបង្គំបែបមិនគួរសមនេះ គឺជាអំពើបាបដោយអចេតនា។ ប៉ុន្តែ អ៊ីស្រាអែលនៅតែមានកំហុសនៅចំពោះព្រះជាម្ចាស់។ នៅក្នុងជំពូកបន្ទាប់ទៀត ៥៩ ព្រះជាម្ចាស់បានហៅអ៊ីស្រាអែលឱ្យបែរចេញពីផ្លូវទុច្ចរិតរបស់ខ្លួន ប្រែចិត្ត នោះនឹងបានស្អាងឡើងវិញដើម្បីទទួលបានព្រះពរដែលព្រះអង្គចង់ប្រទានឱ្យពួកគេ។

ពួកជំនុំអភិវឌ្ឍជាច្រើននៅសព្វថ្ងៃនេះក៏ត្រូវប្រែចិត្តចេញពីការថ្វាយបង្គំបែបមិនគួរសមផងដែរ។ យើងបានយល់តែមួយផ្នែកនៃរបៀបវារៈរបស់ព្រះអង្គតែប៉ុណ្ណោះ គឺផ្នែកខាងវិញ្ញាណ។ យើងមិនបានតំណាងឱ្យព្រះហឫទ័យយកចិត្តទុកដាក់ទាំងមូលរបស់ព្រះជាម្ចាស់ទេ។ យើងម្នាក់ៗ និងពួកជំនុំតាមមូលដ្ឋានរបស់យើងត្រូវប្រែចិត្ត និងឆ្លើយតបតាមរយៈការបន្ទាបខ្លួនថែមទៀត អធិស្ឋាន និងផ្តោតអារម្មណ៏លើភាពខ្ទេចខ្ទាំខាងសាច់ឈាម និងខាងសង្គមនៅក្នុងសហគមន៍របស់យើង។ នៅពេលដែលយើងឮ ហើយស្តាប់បង្គាប់ព្រះជាម្ចាស់ នោះនឹងមានការប្រោសឱ្យជា នឹងមានការបំផ្លាស់បំប្រែ។

សូមឱ្យយើង និងពួកជំនុំមើលឃើញតួនាទីរបស់យើងនៅក្នុងរបៀបវារៈធំរបស់ព្រះជាម្ចាស់! សូមឱ្យយើងបន្ទាបខ្លួន ប្រែចិត្ត និងបម្រើ! សូមឱ្យព្រះជាម្ចាស់ប្រោសស្រុករបស់យើងឱ្យបានជា! សូមឱ្យរាជ្យទ្រង់មកដល់នៅផែនដីដូចជានៅស្ថានសួគ៌ដែរ!

*By Bob Moffitt, Harvest Foundation*

*Last edited by Nadia Chandler and Karla Tesch, August, 2007.*

*Copyright 2007 by the Disciple Nations Alliance*

*701 N. 1st Street Phoenix, AZ 85004*

*email: bmoffitt@harvestfoundation.org*

*www.harvestfoundation.org and www.disciplenations.org*

*ការអនុញ្ញាត: លោកអ្នកត្រូវបានអនុញ្ញាត និងលើកទឹកចិត្តឱ្យថតចម្លង និងចែកចាយមេរៀននេះតាម*
*ទម្រង់ណាមួយក៏បាន តែសូមកុំកែន័យមេរៀន កុំគិតថ្លៃហួសពីលោកអ្នកចំណាយ*
*និងកុំថតចម្លងច្រើនជាង ១000 ច្បាប់ ។*

**Suggested Resources:**

Miller, Darrow L. and Bob Moffitt. *On Earth As It Is in Heaven.* DVD: Session 2. Available through Disciple Nations Alliance: www.disciplenations.org/resources.

Disciple Nations Alliance. www.disciplenations.org/resources/course. Sections: Wholistic Ministry

Harvest Foundation. www.harvestfoundation.org. Sections: Stories

Moffitt, Bob, Tesch, Karla. *If Jesus Were Mayor: How Your Local Church Can Transform Your Community.* Oxford, UK: Monarch Books, 2006, pp. 87-97.

Stark, Rodney. *The Rise of Christianity.* San Francisco CA: HarperCollins Publishers, 1997.